អេស៊ីលីដា
ACLEDA BANK

# របាយការណ៍ ប្រចាំត្រីមាសទី៤

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៣៩.៨០៤.៤០៥ | ៣៧.១៨១.២៩៩ | ៣២.០០២.២៩៨ |
| បំណុលសរុប | ៣៤.១៥៨.៨៥០ | ៣១.៧៦០.៦៦០ | ២៧.០៩២.៩៨៥ |
| មូលធនសរុប | ៥.៦៤៥.៥៥៥ | ៥.៤២០.៦៣៩ | ៤.៩០៩.៣១៣ |
| **លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល)** | **ត្រីមាសទី៤ ឆ្នាំ២០២៣** | **ត្រីមាសទី៤ ឆ្នាំ២០២២** | **ត្រីមាសទី៤ ឆ្នាំ២០២១** |
| ចំណូលសរុប | ៨៧៤.១០២ | ៨០៤.១៥៨ | ៦៧៣.៥៦៩ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ១៨៦.១០៧ | ២៥០.៨៥១ | ២៣៦.១២០ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | ១៥០.៦១២ | ២០១.៤០២ | ១៨៩.៤៦៨ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ៩១.៥០៩ | ១៩៤.០៣១ | ១៥០.១៣២ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី៤ ឆ្នាំ២០២៣** | **ឆ្នាំ២០២២** | **ឆ្នាំ២០២១** |
| អនុបាតសាធនភាព | ១៨,៤៥% | ១៩,២៥% | ២២,៣៦% |
| អនុបាតបំណុលធៀបនឹងមូលធន | ៦០៥,០៦% | ៥៨៥,៩២% | ៥៥១,៨៧% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ១៨០,១៣% | ១៥៤,៩៦% | ១៥៥,៦៥% |
| អនុបាតឥណទានមិនដំណើរការ (*) | ៦,៣៩% | ២,៩០% | ២,៣៣% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៩២,១១% | ១០០,៥១% | ៩៤,៩៧% |
| តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១២.៩៧៧ | ១២.៤៥៦ | ១១.២៧៧ |
| | **ត្រីមាសទី៤ ឆ្នាំ២០២៣** | **ត្រីមាសទី៤ ឆ្នាំ២០២២** | **ត្រីមាសទី៤ ឆ្នាំ២០២១** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)(**) | ០,៣៨% | ០,៥៦% | ០,៦១% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)(**) | ២,៧០% | ៣,៨០% | ៣,៨៧% |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | ១,៥២ | ១,៩២ | ២,២៣ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៣៤៧,៤៩ | ៤៦៥ | ៤៣៧,៣៧ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | គ្មាន | គ្មាន | គ្មាន |

(*) ឥណទានមិនដំណើរការ = ឥណទាននៅដំណាក់កាលទី៣

(**) . អនុបាតទាំងនេះមិនមែនជាអនុបាតប្រចាំឆ្នាំនោះទេ ហើយត្រូវបានគណនាដោយប្រើតួលេខប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគាររយៈពេល ៣ខែ ចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

. អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម = ប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / ទ្រព្យសកម្មសរុបមធ្យម

. អនុបាតចំណេញធៀបនឹងមូលធនមធ្យម = ប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / មូលធនសរុបមធ្យមរបស់ភាគហ៊ុនិករបស់ធនាគារ

## ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប







អនុបាតហិរញ្ញវត្ថុ (%)
១៨,៤៥%
១៩,២៥%
២២,៣៦%
៦០៥,០៦%
៥៨៥,៩២%
៥៥១,៨៧%
១៨០,១៣%
១៥៥,៦៥%
១៥៤,៩៦%
៦,៣៩%
២,៩០%
២,៣៣%
៩២,១១%
១០០,៥១%
៩៤,៩៧%
អនុបាតសាធនភាព
អនុបាតបំណុលធៀបនឹងមូលធន
អនុបាតក្របខ័ណ្ឌសន្ទនីយភាព
អនុបាតឥណទានមិនដំណើរការ
អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ
ត្រីមាសទី៤ ឆ្នាំ២០២៣
ឆ្នាំ២០២២
ឆ្នាំ២០២១


០,៣៨%
០,៥៦%
០,៦១%
២,៧០%
៣,៨០%
៣,៨៧%
អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)
អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)
ត្រីមាសទី៤ ឆ្នាំ២០២៣
ត្រីមាសទី៤ ឆ្នាំ២០២២
ត្រីមាសទី៤ ឆ្នាំ២០២១


ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
៤៣៧,៣៧
៤៦៥
៣៤៧,៤៩
ត្រីមាសទី៤ ឆ្នាំ២០២១
ត្រីមាសទី៤ ឆ្នាំ២០២២
ត្រីមាសទី៤ ឆ្នាំ២០២៣


តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
១១.២៧៧
១២.៤៥៦
១២.៩៧៧
ឆ្នាំ២០២១
ឆ្នាំ២០២២
ត្រីមាសទី៤ ឆ្នាំ២០២៣

# សមាសភាពក្រុមប្រឹក្សាភិបាល



**លោក ឆាយ សឿន**

*ប្រធានក្រុមប្រឹក្សាភិបាល*



**បណ្ឌិត អ៊ិន ចាន់នី**

*អភិបាលប្រតិបត្តិ*



**លោក Stéphane Mangiavacca**

*អភិបាលមិនប្រតិបត្តិ*



**លោក Kyosuke Hattori**

*អភិបាលមិនប្រតិបត្តិ*



**បណ្ឌិត Albertus Bruggink**

*អភិបាលមិនប្រតិបត្តិ*



**លោក កាយ ឡូត**

*អភិបាលមិនប្រតិបត្តិ*



**លោក Pieter Kooi**

*អភិបាលឯករាជ្យ*



**លោកស្រី ភូរិ រតនា**

*អភិបាលឯករាជ្យ*



**បណ្ឌិត ហេង ឌីណា**

*អភិបាលឯករាជ្យ*

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ អេស៊ីលីដា”) និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមផ្តល់ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (“សម្ព័ន្ធធនាគារ”) គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដល់ភាគីពាក់ព័ន្ធទាំងអស់។

នៅក្នុងត្រីមាសទី៤ នៃឆ្នាំ២០២៣ សេដ្ឋកិច្ចពិភពលោក នៅតែប្រឈមនឹងភាពមិនប្រាកដប្រជា ដោយដើមហេតុចម្បងនោះ គឺផលប៉ះពាល់នៃការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ភាពតានតឹងភូមិសាស្ត្រនយោបាយពិភពលោក ជម្លោះក្រុមហាម៉ាស-អ៊ីស្រាអែល វិបត្តិសង្គ្រាមរវាងរុស្ស៊ី-អ៊ុយក្រែន ទីផ្សារអចលនទ្រព្យនៅប្រទេសចិនមានកំណើនយឺត និងការធ្លាក់ចុះដែលមិននឹកស្មានដល់នៅក្នុងពាណិជ្ជកម្មពិភពលោកដែលបណ្តាលមកពីតម្រូវការធ្លាក់ចុះពីប្រទេសចិន។ ស្របពេលជាមួយគ្នានេះដែរ ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក ក៏អាចជះឥទ្ធិពលនៃការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិកអាស៊ានផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចកម្ពុជា នៅតែបន្តរក្សានូវកំណើនល្អប្រសើរ តាមរយៈការងើបឡើងវិញជាបន្តបន្ទាប់ពីជំងឺរាតត្បាត ដែលជំរុញដោយដំណើរការដ៏រឹងមាំក្នុងការនាំចេញផ្នែកផលិតកម្ម ការងើបឡើងវិញបន្តិចម្តងៗនៃវិស័យសេវាកម្ម ដែលគាំទ្រដោយការកើនឡើងចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិ និងការអនុម័តលើគម្រោងវិនិយោគថ្មីៗ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាថ្មីបន្តជួយជំរុញដល់ធុរជនកម្ពុជា និងបរទេស ក្នុងការវិនិយោគលើវិស័យជាច្រើន រួមមាន កសិកម្ម កសិឧស្សាហកម្ម កម្មន្តសាលមិនមែនកាត់ដេរ បច្ចេកវិទ្យាកម្រិតខ្ពស់ និងទេសចរណ៍ ជាដើម។ ការផ្តោតសំខាន់របស់រាជរដ្ឋាភិបាល គឺពង្រីកដល់ការលើកកម្ពស់ធនធានមនុស្សប្រកបដោយវិជ្ជាជីវៈ បង្កើនការធ្វើពិពិធកម្ម ពង្រឹងសមត្ថភាពប្រកួតប្រជែង និងបង្កើនផលិតភាព ដើម្បីធានាបាននូវនិរន្តរភាព និងកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែង។

នៅកំលុងត្រីមាសទី៤ ឆ្នាំ២០២៣នេះ ធនាគារ អេស៊ីលីដា ទទួលបានរបាយការណ៍វាយតម្លៃពីភ្នាក់ងារអន្តរជាតិ Standard & Poor's (S&P) Global Ratings ដោយរក្សានូវចំណាត់ថ្នាក់ "**B+/Stable/B**" ដដែល។ ការរក្សាបាននូវចំណាត់ថ្នាក់នេះ សបញ្ជាក់អំពីភាពរឹងមាំ និងការរក្សាបាននូវស្ថិរភាពប្រវត្តិហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ក្នុងរយៈពេលវែង ជាមួយនឹងទ្រនាប់ដើមទុនគ្រប់គ្រាន់ និងរក្សាបាននូវស្ថិរភាពដើមទុនរបស់ខ្លួនសម្រាប់បង្ការនូវគ្រប់ស្ថានភាពនៃសេដ្ឋកិច្ច ពីវិបត្តិកូវីដ-១៩ និងឧបសគ្គផ្សេងៗ ជាច្រើន ក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ច។ បន្ថែមពីនេះទៀត ធនាគារ អេស៊ីលីដា និងសមាគមកម្ពុជា-ជប៉ុន (JCA) បានរៀបចំកម្មវិធីជំនួបធុរកិច្ចរវាងវិនិយោគិនកម្ពុជា និងជប៉ុន ដែលកម្មវិធីនេះ គឺជាវេទិកាមួយ ដើម្បីផ្លាស់ប្តូរចំណេះដឹងអំពីការគ្រប់គ្រងហិរញ្ញវត្ថុ ចំណេះដឹងបច្ចេកទេស និងការច្នៃប្រឌិតសំខាន់ៗ សម្រាប់ភាពជោគជ័យនៃអាជីវកម្ម ហើយវានឹងបើកឱកាសសម្រាប់វិនិយោគិនកម្ពុជា និងជប៉ុន ណែនាំគ្នាទៅវិញទៅមក។

ធនាគារ អេស៊ីលីដា បានបន្តធ្វើឱ្យប្រសើរឡើងនូវមុខងារស្វ័យប្រតិបត្តិការជាច្រើនលើ**អេស៊ីលីដាម៉ូបាល** ឃ្យូអរកូដ ម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនឆូតកាត ស្របតាមតម្រូវការរបស់អតិថិជន និងវិវឌ្ឍនាការបច្ចេកវិទ្យាឌីជីថល។ ទន្ទឹមនឹងនេះ ធនាគារ អេស៊ីលីដា បានពង្រីកសេវាកម្មធនាគារស្វ័យប្រវត្តិចំនួន**១៧៧**ទីតាំង (រាជធានីភ្នំពេញចំនួន**៦១**ទីតាំង និងបណ្តាខេត្តសរុបចំនួន**១១៦**ទីតាំង) បន្ថែមលើសាខាធនាគារទាំង**២៦៤**សាខា ព្រមទាំងបានបំពាក់ម៉ាស៊ីនអេធីអឹមចំនួន **១.៣៩៣**គ្រឿង ម៉ាស៊ីនឆូតកាតចំនួន**៤.៧២៤**គ្រឿង និងឃ្យូអរកូដតាមសំណើសុំរបស់អតិថិជន សម្រាប់ប្រតិបត្តិការនៃការផ្ទេរ និងការទូទាត់នៅតាមបណ្តាផ្សារ ហាងទំនិញ សណ្ឋាគារ ភោជនីយដ្ឋាន គ្រឹះស្ថានសិក្សា មន្ទីរពេទ្យ ទីភ្នាក់ងារទេសចរណ៍ ស្ថានីយប្រេងឥន្ធនៈ និងអាជីវកម្មនានា នៅទូទាំងប្រទេស។ គិតត្រឹមដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៣នេះ ធនាគារ អេស៊ីលីដា មានដៃគូអាជីវកម្មសរុបជាង**០,៣៣**លាន និងមានអ្នកប្រើប្រាស់ **អេស៊ីលីដាម៉ូបាល** សរុបចំនួន**៣,៣**លាននាក់។

គិតត្រឹមដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៣នេះ ទ្រព្យសកម្មសរុបរបស់សម្ព័ន្ធធនាគារ បានកើនឡើងចំនួន**៧១២,៨៤**លានដុល្លារអាមេរិក ឬ**៧,៨៩%** និងទ្រព្យសកម្មឥណទានសរុបបានកើនឡើងចំនួន**២៣៩,៦៦**លានដុល្លារអាមេរិក ឬ **៣,៦៧%** ធៀបនឹងដំណាច់ឆ្នាំ២០២២។

សម្ព័ន្ធធនាគារ (សម្រាប់ខែតុលា វិច្ឆិកា និងធ្នូ ឆ្នាំ២០២៣) ទទួលបានប្រាក់ចំណេញសរុបចំនួន**៣៦,៥៤**លានដុល្លារអាមេរិក ខណៈដែលអនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យមមានចំនួន**០,៣៨%** និងអនុបាតចំណេញធៀបនឹងមូលធនមធ្យមមានចំនួន**២,៧០%**។

ជាទីបញ្ចប់ ខ្ញុំបាទសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះភាគីពាក់ព័ន្ធទាំងអស់ដែលបានបន្តផ្តល់ការជ្រោមជ្រែង និងការគាំទ្រដល់ធនាគារ អេស៊ីលីដា។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៤
ហត្ថលេខា និងត្រា

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

**ឆាយ សឿន**

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii

សមាសភាពក្រុមប្រឹក្សាភិបាល ........ v

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ vi

ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ខ- លក្ខណៈនៃធុរកិច្ច ........ ១

គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ៣

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ........ ៣

ខ- រចនាសម្ព័ន្ធចំណូល ........ ៥

ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ........ ៥

ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........ ៦

ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ ៦

ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ ៩

គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ ១០

ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ ១១

ង- ផលប៉ះពាល់នៃអតិផរណា ........ ១១

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ........ ១២

ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១៤

## ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

### ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ជាអក្សរឡាតាំង | **ACLEDA Bank Plc.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ធ.ព.០៦ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយនិយ័តករមូលបត្រកម្ពុជា “ន.ម.ក.” (ពីមុនជា គណៈកម្មការមូលបត្រកម្ពុជា “គ.ម.ក.”) |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

### ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ផមក) ចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះ ធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ (១) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (២) ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៣) ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី និង (៤) វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ព្រមទាំងមានការិយាល័យតំណាងចំនួន១នៅប្រទេសមីយ៉ាន់ម៉ា។

### គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

- នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា បានទទួលពានរង្វាន់ ចំនួន ២ ជា**ធនាគារឈានមុខក្នុងតំបន់អាស៊ី** ក្នុងការផ្តួចផ្តើមបរិយាបន្នហិរញ្ញវត្ថុ និងជាធនាគារ អេស៊ីលីដា ដែលបំពាក់បច្ចេកវិទ្យាសេវាធនាគារតាមទូរស័ព្ទដៃខ្ពស់បំផុត ក្នុងការបម្រើសេវាកម្មហិរញ្ញវត្ថុ។
- នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា បានទទួលពានរង្វាន់ ជាដៃគូប្រតិបត្តិការទូទាត់ឆ្នើម ប្រចាំឆ្នាំ២០២២ ពីស្ថាប័ន BNY Mellon។
- នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា ទទួលបានរបាយការណ៍វាយតម្លៃពីភ្នាក់ងារអន្តរជាតិ **Standard & Poor's (S&P) Global Ratings** ដោយរក្សានូវចំណាត់ថ្នាក់ "**B+/Stable/B**" ដដែល។ ការរក្សាបាននូវចំណាត់ថ្នាក់នេះ

សបញ្ជាក់អំពីភាពរឹងមាំ និងការរក្សាបាននូវស្ថិរភាពប្រតិបត្តិហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ក្នុងរយៈពេលវែង ជាមួយនឹងទ្រនាប់ដើមទុនគ្រប់គ្រាន់ និងរក្សាបាននូវស្ថិរភាពដើមទុនរបស់ខ្លួនសម្រាប់បង្ការនូវគ្រប់ស្ថានភាពនៃសេដ្ឋកិច្ច ពីវិបត្តិកូវីដ-១៩ និងឧបសគ្គផ្សេងៗ ជាច្រើន ក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ច។

- នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា បានទទួលលិខិតថ្លែងអំណរគុណពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលធនាគារបានឧបត្ថម្ភក្នុងកម្មវិធី "**ពិព័រណ៍អប់រំឆ្នាំ២០២៣**"។
- នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារ បានទទួលលិខិតថ្លែងអំណរគុណ ពីសមាគមសហគ្រិនស្ត្រីកម្ពុជា ដែលធនាគារបានឧបត្ថម្ភក្នុងកម្មវិធី "**ទិវាសហគ្រិនស្ត្រីកម្ពុជា**" ក្រោមប្រធានបទ៖ បញ្ហាប្រឈមរបស់សហគ្រិនស្ត្រីលើកាតព្វកិច្ចពន្ធ និងទស្សនៈវិស័យនាពេលអនាគត។
- នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា និងសមាគមកម្ពុជា-ជប៉ុន (JCA) បានរៀបចំកម្មវិធីជំនួបធុរកិច្ច រវាងវិនិយោគិនកម្ពុជា និងជប៉ុន ដែលកម្មវិធីនេះ គឺជាវេទិកាមួយ ដើម្បីផ្លាស់ប្តូរចំណេះដឹងអំពីការគ្រប់គ្រងហិរញ្ញវត្ថុ ចំណេះដឹងបច្ចេកទេស និងការច្នៃប្រឌិតសំខាន់ៗ សម្រាប់ភាពជោគជ័យនៃអាជីវកម្ម ហើយវានឹងបើកឱកាសសម្រាប់វិនិយោគិនកម្ពុជា និងជប៉ុន ណែនាំគ្នាទៅវិញទៅមក។ ព្រឹត្តិការណ៍ដ៏សំខាន់នេះ មានការចូលរួមប្រមាណ ៦០ ក្រុមហ៊ុន ទាំងវិនិយោគិនក្នុងស្រុក និងវិនិយោគិនជប៉ុន រួមមាន សហគ្រាសធុនតូចនិងមធ្យម ឧស្សាហកម្ម អ្នកបច្ចេកទេសជួសជុលនិងថែទាំយានយន្ត សាលាកែសម្ផស្ស បច្ចេកវិទ្យាព័ត៌មាន អ្នកទីផ្សារ និងអ្នកផ្សព្វផ្សាយការលក់ វេជ្ជសាស្ត្រ កសិកម្ម អចលនទ្រព្យ ហិរញ្ញវត្ថុ ទេសចរណ៍ និងបដិសណ្ឋារកិច្ច ជាដើម។
- នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា បានទទួលពានរង្វាន់ជាធនាគារដៃគូឈានមុខគេ ក្នុងឆ្នាំ២០២៣ ពីស្ថាប័ន **Mastercard** ដូចជាពានរង្វាន់ជាស្ថាប័នដែលមានកំណើនខ្ពស់សម្រាប់ប័ណ្ណឥណទាន និងប័ណ្ណឥណពន្ធ និងមានការទូទាត់អន្តរជាតិច្រើនជាងគេ។
- នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣ ធនាគារជាតិ នៃ កម្ពុជា និងធនាគារកណ្តាលវៀតណាម បានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធទូទាត់តាមឃ្យូអរកូដឆ្លងដែន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជាមួយនឹងប្រតិបត្តិការទូទាត់ឆ្លងដែន រវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងព្រះរាជាណាចក្រកម្ពុជា។ ធនាគារ អេស៊ីលីដា និងធនាគារ Bank for Investment and Development of Vietnam (BIDV) ត្រូវបានជ្រើសរើសជាធនាគារទំនាក់ទំនង (Sponsoring Bank) សម្រាប់ការទូទាត់ឆ្លងដែនតាមឃ្យូអរកូដ (QR Code) នៅប្រទេសកម្ពុជា និងវៀតណាម ដើម្បីសម្រួលដល់ការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗ និងលើកកម្ពស់ការទូទាត់រូបិយវត្ថុជាតិ (ប្រាក់រៀល) ឱ្យកាន់តែទូលំទូលាយ និងជំរុញបរិយាបន្នហិរញ្ញវត្ថុនៅក្នុងតំបន់ស្របតាមសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន។
- នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ ថ្នាក់ដឹកនាំ និងកម្មករនិយោជិតធនាគារ អេស៊ីលីដា គ្រប់លំដាប់ថ្នាក់នៅការិយាល័យកណ្តាល និងសាខាជុំវិញរាជធានីភ្នំពេញ បានចូលរួមបរិច្ចាគឈាមដោយស្ម័គ្រចិត្ត ដើម្បីជួយសង្គ្រោះជនរងគ្រោះ និងអ្នកជំងឺដែលត្រូវការឈាម។ ការបរិច្ចាគឈាមពិតជាមានសារសំខាន់ខ្លាំងណាស់ក្នុងការជួយសង្គ្រោះជនរងគ្រោះ និងអ្នកជំងឺដែលត្រូវការឈាមដើម្បីព្យាបាលជំងឺ។ ការចូលរួមចំណែកក្នុងកិច្ចការសង្គមដ៏មានសារសំខាន់មួយនេះ ថ្នាក់ដឹកនាំ និងកម្មករនិយោជិត ធនាគារបានចូលរួមបរិច្ចាគឈាមដោយស្ម័គ្រចិត្តចំនួន ៧ដង រួចមកហើយ ដើម្បីរួមចំណែកក្នុងសកម្មភាពសង្គម និងមនុស្សធម៌ សម្រាប់បំពេញតម្រូវការកង្វះឈាមក្នុងការជួយសង្គ្រោះអាយុជីវិត ជូនដល់មជ្ឈមណ្ឌលជាតិផ្តល់ឈាម សម្រាប់ជួយសង្គ្រោះជនរងគ្រោះ និងអ្នកជំងឺដែលត្រូវការឈាមជាចាំបាច់ ជាពិសេសសម្រាប់ជួយជីវិតមនុស្សដែលត្រូវការសង្គ្រោះបន្ទាន់។
- នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា បានទទួលលិខិតថ្លែងអំណរគុណ ដែលធនាគារ បានឧបត្ថម្ភក្នុងកម្មវិធី CSX Fun Run ដែលរៀបចំដោយផ្សារមូលបត្រកម្ពុជា ក្នុងគោលបំណងបំផុសចលនាចូលរួមលេងកីឡា និងកៀរគរថវិកាបរិច្ចាគជូនមូលនិធិគន្ធបុប្ផាកម្ពុជា។

# ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

- **<u>ប្រតិបត្តិការក្នុងវិស័យធនាគារ</u>**

ត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៣ ធនាគារពាណិជ្ជមានចំនួន៥៨ (ធនាគារក្នុងស្រុកចំនួន២៩ បុត្រសម្ព័ន្ធធនាគារបរទេសចំនួន១៨ និងសាខាធនាគារបរទេសចំនួន១១) ធនាគារឯកទេសចំនួន០៩ (ធនាគារក្នុងស្រុកចំនួន០៤ និងធនាគារបរទេសចំនួន០៥) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨៧ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៤ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៨៣) ក្រុមហ៊ុនភតិសន្យាចំនួន១៦ ការិយាល័យតំណាងធនាគារបរទេសចំនួន០៥ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន៣៣ គ្រឹះស្ថានឥណទានជនបទចំនួន១១៤ និង ភ្នាក់ងារប្តូរប្រាក់ចំនួន២.៩១៥។ (Source: NBC Report, CMA Report, Actually Updated)

- **<u>ប្រតិបត្តិការអាជីវកម្ម និងចំណែកទីផ្សាររបស់ធនាគារ អេស៊ីលីដា នៅក្នុងវិស័យធនាគារ</u>**

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានចំណែកទីផ្សារសម្រាប់ប្រាក់បញ្ញើសន្សំចំនួន ១៥,៣៧% និងសម្រាប់ឥណទានចំនួន ១២,៤៩%។

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៣ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
| **សេវាឥណទាន** | | | |
| ចំនួនឥណទានសកម្ម | ៦៦១.៩៤១ | ៥៩១.៤៩៤ | ៥៤១.១៨៤ |
| សមតុល្យឥណទានសរុប (លានរៀល) | ២៧.១៩៥.១២០ | ២៦.៤៣៧.៩២៨ | ២២.១១៦.០១៣ |
| **សេវាបញ្ញើ-សន្សំ** | | | |
| ចំនួនគណនីសរុប | ៤.៥៥០.៥៨២ | ៣.៨៦៥.៧៤៩ | ៣.២៩៨.៣៨២ |
| សមតុល្យប្រាក់បញ្ញើសរុប (លានរៀល) | ២៩.៥២៥.៦១៦ | ២៦.៣០៣.៤៧៥ | ២៣.២៨៧.០៦៤ |
| **សេវាធនាគារអេឡិចត្រូនិក** | | | |
| **ប័ណ្ណអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណបោះផ្សាយសរុប | ១.៩៣៩.០៩៨ | ១.៧៩៩.៩០៩ | ១.៥៨៥.៤៤៩ |
| ចំនួនប្រតិបត្តិការសរុប | ១៩.៨៥១.៨០១ | ២១.០៥៨.៦០៩ | ១៩.៤៤៨.៨៣៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៧.១៤៥.៤១១ | ១៨.៦៨៣.៣៣៥ | ១៦.១៧៣.៩៩០ |
| **អេស៊ីលីដាម៉ូបាល** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ៣.៤៥១.៦០៦ | ២.៨៤៥.៨៨៦ | ២.២៧៨.២២០ |
| ចំនួនប្រតិបត្តិការសរុប | ៣៧៣.០៣៦.៣៣៦ | ១៤៨.៧៩៩.៦៦១ | ៧៨.៧២៦.៨៩៥ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣៨៣.០៤៣.៥៩៦ | ២០៦.៦៦០.២៦២ | ១១៥.២៤២.៦៣៨ |
| **អេស៊ីលីដាអ៊ីនធឺណែត** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២៤.៨២៥ | ២២.១៦៤ | ១៣.៥៥៧ |
| ចំនួនប្រតិបត្តិការសរុប | ៣.៥២៩.២០៩ | ២.៣១៨.៧៨៩ | ១.៤៦៦.៨២២ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២៦.៥២៩.៣៨១ | ២៦.១៥៨.៧០៥ | ១៩.៧៩៩.៨៦៤ |
| **អេស៊ីលីដាអ៊ីខុមមើស** | | | |
| ចំនួនដៃគូអាជីវកម្មសរុប | ៨៨ | ៧៣ | ៥៩ |
| ចំនួនប្រតិបត្តិការសរុប | ៣.៩៨៣.១៦៧ | ៣.៦១៩.៩៣៦ | ៣.២១៥.២០៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២.០១៩.០០១ | ១.៨០៤.១៣៦ | ១.២០៦.៥២៩ |
| **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនសរុប | ១.៣១៤ | ១.១១៤ | ៩០១ |
| ចំនួនប្រតិបត្តិការសរុប | ៤១.៥៥៤.៩៩៣ | ៣៥.២៩៨.២១៤ | ២៧.១២៩.២៥២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៤៦.៨០១.៩៨២ | ៣៩.១៦០.៩៧៦ | ២៦.៤៧៧.៣៤១ |
| **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** | | | |
| ចំនួនម៉ាស៊ីនសរុប | ២៦ | ២៦ | ២៦ |
| ចំនួនប្រតិបត្តិការសរុប | ៣០៤ | ១.៤៨៧ | ៤.១២០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៦.១៤៣ | ១១១.១៣៤ | ៣៤៣.១៥៨ |
| **ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម** | | | |
| ចំនួនម៉ាស៊ីនសរុប | ៩៦ | ៤៣ | ២៥ |
| ចំនួនប្រតិបត្តិការសរុប | ១៣០.៩៨៧ | ៤៣.០៨៩ | ៣៤.០៩២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៥ | ១៦ | ៧០ |
| **ម៉ាស៊ីនទទួលកាបូបប្រាក់** | | | |
| ចំនួនម៉ាស៊ីនសរុប | ១៧ | ១៧ | ១៤ |
| ចំនួនប្រតិបត្តិការសរុប | ៨៨.៩០៨ | ៧៥.០២០ | ៩៤.៧១៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៥០៦.៥៥០ | ៥៧១.០៩៨ | ៥៥៥.២៥៧ |
| **ម៉ាស៊ីនឆូតកាតអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនឆូតកាតសរុប | ៤.៧២៨ | ៤.៣៥៨ | ៤.៤៦២ |
| ចំនួនប្រតិបត្តិការសរុប | ១.៩០០.៤០០ | ២.១៥៩.១៧៥ | ២.០៣៣.២៨៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៦១៤.៤០៣ | ៥៩១.៦០៣ | ៤៧៩.៦១៣ |
| **ឃ្យូអរ ពាណិជ្ជករ** | | | |
| ចំនួនពាណិជ្ជករ | ៣៨២.២១៧ | ២៣៩.៧៥១ | ១២៥.៣០៩ |
| ចំនួនប្រតិបត្តិការសរុប | ១១០.១៤៨.៨៤៨ | ១៦.៤៥៩.៣៧៧ | ៣.១៩៤.៤៤៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៦៣.១៧៥.៧២០ | ៧.៧៧៧.៤៩១ | ៦៣៨.២៤០ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
| **ប័ណ្ណនិមិ្មតអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណនិម្មិត | ២៧.១០៦ | ៨.៨៩៨ | ៣.៦៨៤ |
| ចំនួនប្រតិបត្តិការសរុប | ១៨២.៣៧៦ | ៣៤.៩០៧ | ២.៤៩១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៨.៨១៨ | ៣.០១៨ | ១៦១ |
| **ខ្សែអាយប៉ែង** | | | |
| ចំនួនខ្សែបោះផ្សាយសរុប | ១០.៦០៣ | ៤.៩៦០ | - |
| ចំនួនប្រតិបត្តិការសរុប | ១២.៧១០ | ១៨.៧៤២ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៤.៥១១ | ៣១.៧៦២ | - |
| **បណ្ដាញប្រតិបត្តិការ និង បុគ្គលិក** | | | |
| **ធនាគារ អេស៊ីលីដា ភីអិលស៊ី** | | | |
| ចំនួនការិយាល័យសរុប | ២៦៤ | ២៦៤ | ២៦២ |
| ចំនួនធនាគារស្វ័យប្រវត្តិ | ១៧៧ | ១២៥ | ៧៣ |
| ចំនួនបុគ្គលិកសរុប | ១២.០៤៥ | ១២.០៨៣ | ១២.០៨១ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស)** | | | |
| ចំនួនការិយាល័យសរុប | ៥៦ | ៥៦ | ៥៧ |
| ចំនួនបុគ្គលិកសរុប | ១.៤៥៨ | ១.៤៩៩ | ១.៥៩៣ |

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៣ | | ត្រីមាសទី៤ ឆ្នាំ២០២២ | | ត្រីមាសទី៤ ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៨០០.៩៥០ | ៩១,៦៣% | ៧៣៤.៤៦០ | ៩១,៣៣% | ៦០២.១២៨ | ៨៩,៣៩% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៧.៩០២ | ៥,៤៨% | ៤៦.៧៨៩ | ៥,៨២% | ៤២.៩៦៨ | ៦,៣៨% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ២៥.២៥០ | ២,៨៩% | ២២.៩០៩ | ២,៨៥% | ២៨.៤៧៣ | ៤,២៣% |
| | **ចំណូលសរុប** | **៨៧៤.១០២** | **១០០%** | **៨០៤.១៥៨** | **១០០%** | **៦៧៣.៥៦៩** | **១០០%** |

# ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ
របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ

## ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុចន្លោះពេលត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”)។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារ អេស៊ីលីដាភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (“សម្ព័ន្ធធនាគារ”) ប៉ុណ្ណោះ ត្រូវបានយកមកធ្វើការពិភាក្សា និងវិភាគ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

សម្ព័ន្ធធនាគារ មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗសុទ្ធ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃនិងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗសុទ្ធ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ-សុទ្ធ ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

### ២- ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៣ | | ត្រីមាសទី៤ ឆ្នាំ២០២២ | | ត្រីមាសទី៤ ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៨០០.៩៥០ | ៩១,៦៣% | ៧៣៤.៤៦០ | ៩១,៣៣% | ៦០២.១២៨ | ៨៩,៣៩% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៧.៩០២ | ៥,៤៨% | ៤៦.៧៨៩ | ៥,៨២% | ៤២.៩៦៨ | ៦,៣៨% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ២៥.២៥០ | ២,៨៩% | ២២.៩០៩ | ២,៨៥% | ២៨.៤៧៣ | ៤,២៣% |
| | **ចំណូលសរុប** | **៨៧៤.១០២** | **១០០%** | **៨០៤.១៥៨** | **១០០%** | **៦៧៣.៥៦៩** | **១០០%** |

ចំណូលសរុបនៅត្រីមាសទី៤ ឆ្នាំ២០២៣ បានកើនឡើងចំនួន ៦៩,៩៤ ប៊ីលានរៀល ឬ ៨,៧០% បើប្រៀបធៀបទៅនឹងត្រីមាសទី៤ ឆ្នាំ២០២២ ដែលការកើនឡើងទាំងនេះគឺដោយសារប្រសិទ្ធភាពនៃផលិតផល និងសេវាកម្មដ៏សម្បូរបែបរបស់ធនាគារក្នុងយុគសម័យឌីជីថល និងកំណើនអតិថិជន។

### ៣- ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់សម្ព័ន្ធធនាគារ បានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុបនឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ដូចខាងក្រោម។

## ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៣ | ត្រីមាសទី៤ ឆ្នាំ២០២២ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៨០០.៩៥០ | ៧៣៤.៤៦០ | ៦៦.៤៩០ | ៩,០៥% |
| ចំណាយការប្រាក់ | (៣៥៨.៦៤៣) | (២៧១.២៩២) | (៨៧.៣៥១) | ៣២,២០% |
| **ចំណូលការប្រាក់សុទ្ធ** | **៤៤២.៣០៧** | **៤៦៣.១៦៨** | **(២០.៨៦១)** | **(៤,៥០%)** |
| ចំណូលកម្រៃនិងជើងសា | ៤៧.៩០២ | ៤៦.៧៨៩ | ១.១១៣ | ២,៣៨% |
| ចំណាយកម្រៃនិងជើងសា | (៣.៨៧៣) | (៤.៨០៧) | ៩៣៤ | (១៩,៤៣%) |
| **ចំណូលកម្រៃនិងជើងសាសុទ្ធ** | **៤៤.០៣០** | **៤១.៩៨២** | **២.០៤៨** | **៤,៨៨%** |
| សំវិធានធននៃការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាននិងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗ គណនីត្រូវទទួល និងមូលបត្រវិនិយោគផ្សេងៗ | (៤៧.៩៣៣) | (២.៤៤៤) | (៤៥.៤៨៩) | ១.៨៦១,២៥% |
| (សំវិធានធន)/ការកត់ត្រាត្រឡប់នៃការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ | (២) | ១ | (៣) | ៣០០% |
| **ការខាតបង់ឱនភាពនៃតម្លៃសុទ្ធ** | **(៤៧.៩៣៥)** | **(២.៤៤៣)** | **(៤៥.៤៩២)** | **១.៨៦២,១៤%** |
| **ចំណូលបន្ទាប់ពីការខាតបង់ឱនភាពនៃតម្លៃ** | **៤៣៨.៤០២** | **៥០២.៧០៧** | **(៦៤.៣០៥)** | **(១២,៧៩%)** |
| ចំណូលផ្សេងៗសុទ្ធ | ២៥.២៥០ | ២២.៩០៩ | ២.៣៤១ | ១០,២២% |
| ចំណាយទូទៅនិងរដ្ឋបាល | (២៧៧.៥៤៥) | (២៧៤.៧៦៤) | (២.៧៨១) | ១,០១% |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **១៨៦.១០៧** | **២៥០.៨៥១** | **(៦៤.៧៤៤)** | **(២៥,៨១%)** |

ការកើនឡើងនូវភាពជឿជាក់របស់អតិថិជនមកលើសម្ព័ន្ធធនាគារ ធ្វើឱ្យប្រាក់បញ្ញើនៅដំណាច់ខែធ្នូ ឆ្នាំ២០២៣ កើនឡើងដល់ ២៩,៥៣ ទ្រីលានរៀល ដែលបានកើនឡើងចំនួន ៣,២២ ទ្រីលានរៀល ឬ ១២,២៥% ពីដំណាច់ខែធ្នូ ឆ្នាំ២០២២។ ដោយអនុវត្តតាមបទប្បញ្ញត្តិទាក់ទងនឹងការធ្វើចំណាត់ថ្នាក់ឥណទាន និងដើម្បីភាពរឹងមាំ និងការទប់ទល់រាល់ហានិភ័យ ដែលអាចជះឥទ្ធិពលដល់ឥណទាននិងបុរេប្រទានដល់អតិថិជន ជាពិសេសហានិភ័យដែលអាចកើតចេញពីកូវីដ-១៩ ធនាគារបានបង្កើននូវសំវិធានធននៃការខាតបង់ឱនភាពនៃតម្លៃចំនួន ៤៥,៤៩ ប៊ីលានរៀល ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២។

## ៥- ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៣ | ត្រីមាសទី៤ ឆ្នាំ២០២២ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **១៨៦.១០៧** | **២៥០.៨៥១** | **(៦៤.៧៤៤)** | **(២៥,៨១%)** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៣៥.៤៩៦) | (៤៩.៤៤៩) | ១៣.៩៥៣ | (២៨,២២%) |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៥០.៦១២** | **២០១.៤០២** | **(៥០.៧៩០)** | **(២៥,២២%)** |

## ៦- ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៣ | ត្រីមាសទី៤ ឆ្នាំ២០២២ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៥០.៦១២** | **២០១.៤០២** | **(៥០.៧៩០)** | **(២៥,២២%)** |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | |
| ***ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញ ឬខាត៖*** | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | - | ១.៩៣៦ | (១.៩៣៦) | (១០០%) |
| លម្អៀងពីអត្រាប្តូរប្រាក់ | (៥១.០៣០) | (២.៤៥៧) | (៤៨.៥៧៣) | (១.៩៧៦,៩២%) |
| ***ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅគ្រាបន្ទាប់ទៅចំណេញ ឬខាត៖*** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ-ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស | ៤.៣០៤ | (៤.៧៤៨) | ៩.០៥២ | ១៩០,៦៥% |
| ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធភាពរបស់ឧបករណ៍និស្សន្ទដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់ | (១២.៣៧៧) | (២.១០២) | (១០.២៧៥) | (៤៨៨,៨២%) |
| **លទ្ធផលលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ** | **(៥៩.១០៣)** | **(៧.៣៧១)** | **(៥១.៧៣២)** | **(៧០១,៨៣%)** |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **៩១.៥០៩** | **១៩៤.០៣១** | **(១០២.៥២២)** | **(៥២,៨៤%)** |

## ៧- ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ធនាគារ អេស៊ីលីដា មានទំនុកចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការរបស់ខ្លួន ចំពេលការព្យាករកំណើនសេដ្ឋកិច្ចមានសញ្ញាល្អប្រសើរឡើង បន្ទាប់ពីបានកសាងកេរ្តិ៍ដំណែលដ៏រឹងមាំអស់រយៈពេលច្រើនជាង៣០ឆ្នាំកន្លងមកនេះ ធនាគារ អេស៊ីលីដា បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ពេលអនាគត ហើយនឹងនៅតែបន្តចាត់គ្រឹះឱ្យកាន់តែរឹងមាំដើម្បីផ្តល់ជូននូវដំណោះស្រាយក្នុងវិស័យធនាគារឱ្យកាន់តែសម្បូរបែប ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការផ្នែកហិរញ្ញវត្ថុរបស់អតិថិជនទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជា។

បន្ទាប់ពីបំបែកព្រំដែនភូមិសាស្ត្រ ដោយការដាក់បញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងរូបវន្ត ធនាគារដែលបានបង្កើតឡើងនៅក្នុងស្រុកមួយនេះ កំពុងផ្តល់ជូននូវសេវាកម្មធនាគារសម្រាប់មូលដ្ឋានអតិថិជនចម្រុះដោយជោគជ័យ ដែលមានរាប់ចាប់តាំងពីសេវាធនាគារបុគ្គល និងសម្រាប់សាជីវកម្ម ទាំងនៅក្នុងទីក្រុង រហូតដល់តំបន់ជនបទ។ ជាមួយនឹងភាពលេចធ្លោក្នុងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដ៏សម្បូរបែប ដូចជាផ្តល់ប្រាក់កម្ចី ផ្ទេរប្រាក់ ប្រាក់បញ្ញើ ហិរញ្ញប្បទានពាណិជ្ជកម្ម អេស៊ីលីដាអ៊ីនធើណែត **អេស៊ីលីដា ម៉ូបាល** និងសេវាសំខាន់ជាច្រើនទៀត គាំទ្រដោយហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការិយាល័យរូបវន្តរបស់ខ្លួន ធនាគារ អេស៊ីលីដា កំពុងចូលរួមយ៉ាងសកម្មក្នុងការជួយដល់កសិករ តាមរយៈការផ្តល់ដើមទុនសម្រាប់ធ្វើស្រែចម្ការរបស់គាត់ ឬផ្តល់ទុនសម្រាប់សហគ្រាសធុនតូច និងមធ្យមជាដើម។ តាមរយៈការបង្រួមគម្លាតចំពោះការទទួលបានហិរញ្ញប្បទាន សព្វថ្ងៃនេះប្រជាជនកម្ពុជាច្រើនជាងកន្លះលាននាក់ មានលទ្ធភាពប្រើប្រាស់សេវារបស់ធនាគារ អេស៊ីលីដា ដែលជាការជំរុញនិងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីរយៈពេលច្រើនជាង៣០ឆ្នាំមកនេះ គេនឹងមើលឃើញ ធនាគារ អេស៊ីលីដា គឺជាធនាគារឌីជីថល ដែលមានវិស្វកម្មគ្រប់គ្រងទិន្នន័យទំនើបទាន់សម័យ (Data Lakehouse) ប្រកបដោយគុណភាព សុវត្ថិភាព និងទំនុកចិត្ត។ ប្រព័ន្ធអេកូនៃបណ្តាញប្រកបដោយប្រសិទ្ធភាពរបស់ធនាគារនៅទូទាំងប្រទេស រួមមានម៉ាស៊ីន ATM ទីតាំងធនាគារស្វ័យប្រវត្តិ ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ កំពុងដើរតួជាកាតាលីករដ៏មានឥទ្ធិពលមួយសម្រាប់រលកនៃកំណើនបន្ទាប់។

អនាគតរបស់ធនាគារនឹងកាន់តែរឹងមាំ ខណៈទំនុកចិត្តរបស់អាជីវកម្មលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជានឹងកើនឡើង បន្ទាប់ពីរាជរដ្ឋាភិបាលបានទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទស្សនវិស័យកំណើនរបស់ប្រទេសកម្ពុជា ត្រូវបានរំពឹងថានឹងងើបឡើងវិញនៅពេលដែលការរឹតបន្តឹងបញ្ហាកូវីដ-១៩ ត្រូវបានដកចេញ។

ការងើបឡើងវិញនៃការនាំចេញផ្នែកផលិតកម្ម និងការពង្រីកការនាំចេញទំនិញកសិកម្ម នឹងមានភាពល្អប្រសើរសម្រាប់ធនាគារអេស៊ីលីដា ដោយសារអ្នកទទួលកម្ចីភាគច្រើនមានអាជីវកម្មទាក់ទងនឹងកសិផល។ ធនាគារនឹងសម្រេចបានលទ្ធផលកាន់តែល្អប្រសើរនៅក្នុងឆ្នាំ២០២៤ ដោយសារធនាគារបានវិនិយោគយ៉ាងច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល សាងសង់មជ្ឈមណ្ឌលទិន្នន័យដ៏ធំមួយ ដែលមានសុវត្ថិភាពខ្ពស់ដើម្បីរក្សាទុកទិន្នន័យ។ ការសាងសង់មជ្ឈមណ្ឌលការពារទិន្នន័យ (Disaster Recovery Data Center) នឹងជួយរក្សាទិន្នន័យនៅក្នុងបរិយាកាសដែលមានការការពារខ្ពស់។ ធនាគារមានទំនុកចិត្តចំពោះពេលអនាគត ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងផលិតផល-សេវាកម្ម ដែលនឹងកាន់តែមានភាពល្អប្រសើរ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

សម្ព័ន្ធធនាគារ ទទួលបានជោគជ័យនៅលើទីផ្សារអាស្រ័យដោយកត្តាពីរគឺ៖

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់សម្ព័ន្ធធនាគារ ជាពិសេសសហគ្រាសធុនតូច និងមធ្យម។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់សម្ព័ន្ធធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់សម្ព័ន្ធធនាគារ ដែលផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

សម្ព័ន្ធធនាគារ បាននិងកំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធចម្រុះឱ្យកាន់តែទូលំទូលាយសម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយនឹងការិយាល័យទាំង៣២០ តាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗទៅជាមជ្ឈមណ្ឌលដែលអាចធ្វើស្វ័យប្រតិបត្តិការដែលមានទីតាំងធនាគារស្វ័យប្រវត្តិចំនួន១៧៧ ព្រមទាំងមាន **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** ចំនួន១.៣១៤ គ្រឿង **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** ចំនួន២៦គ្រឿង **ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម** ចំនួន៩៦ គ្រឿង **ម៉ាស៊ីនទទួលកាបូបប្រាក់** ចំនួន១៧ គ្រឿង និង **ម៉ាស៊ីនឆូតកាត**ចំនួន៤.៧២៨ គ្រឿង។ ចំណុចគួរជាទីមោទនភាពគឺសម្ព័ន្ធធនាគារ បានបោះពុម្ពប័ណ្ណ**អេធីអឹមអេស៊ីលីដា** ចំនួន ១,៩៤ លានប័ណ្ណជូនដល់អតិថិជន។ ទន្ទឹមនឹងនេះ **អេស៊ីលីដាម៉ូបាល** បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំង ដែលចំនួននៃអ្នកចុះឈ្មោះប្រើប្រាស់បានកើនដល់ ៣,៤៥ លាននាក់ នៅដំណាច់ខែធ្នូ ឆ្នាំ២០២៣នេះ ដែលអាចជួយឱ្យចរាចរសាច់ប្រាក់បានឆាប់រហ័សនៅក្នុងសេដ្ឋកិច្ច។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ិនធើណែត គឺជាចំណុចដែលសម្ព័ន្ធធនាគារ ផ្តោតការយកចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ សម្ព័ន្ធធនាគារ នឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីកនិងកែលម្អដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្ត្រ សម្ព័ន្ធធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជនដ៏

ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់ពួកគាត់ផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្មទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់សម្ព័ន្ធធនាគារ និងរីកចម្រើនជាមួយគ្នា។

**អេស៊ីលីដាម៉ូបាល** ត្រូវបានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាមួយនឹងមុខងារពិសេសៗជាច្រើន។ ឥឡូវនេះ អតិថិជនទាំងអស់អាចធ្វើប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ **អេស៊ីលីដាម៉ូបាល** បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។

**ខេអេចឃ្យូអរកូដ (KHQR Code)** ផ្តល់នូវភាពងាយស្រួលជាងមុនជូនដល់អ្នកប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងទំនុកចិត្តខ្ពស់ រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាសមាជិករបស់កម្មវិធីបាគង (**Bakong App**)។

ឥឡូវនេះ ជាមួយ**អេស៊ីលីដាម៉ូបាល** ពិតជាងាយស្រួល ដោយលោកអ្នកអាចទូទាត់ផ្សេងៗ តាម QR Code (Scan QR) បានគ្រប់ទីកន្លែង នៅទូទាំងប្រទេសថៃ វៀតណាម និងឡាវ ដោយឥតគិតថ្លៃសេវា។ នេះជាភាពជោគជ័យថ្មីមួយទៀតរបស់ប្រព័ន្ធបាគង និងធនាគារ អេស៊ីលីដា ដែលជាសមាជិករបស់បាគង។

## ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

## ៣- ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ **"មាស"** ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ២០២២ ដល់២០២៣ ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

ចំណូលពន្ធគឺជាប្រភពចំណូលដ៏សំខាន់បំផុតសម្រាប់ប្រទេស។ រដ្ឋាភិបាលប្រមូលពន្ធកាន់តែច្រើន ការចូលរួមវិភាគទានកាន់តែច្រើនដល់ការអភិវឌ្ឍប្រទេស។ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបង់ពន្ធច្រើនជាងគេជាប់ចំណាត់ថ្នាក់លេខ៣ និងបង់ពន្ធលើប្រាក់ចំណូលជាប់ចំណាត់ថ្នាក់លេខ៤ ក្នុងចំណោមសហគ្រាសដែលបានបង់ពន្ធច្រើនជាងគេប្រចាំឆ្នាំ២០២២។ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានមោទនភាពដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើង។

## ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

សម្ព័ន្ធធនាគារ មិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសវីរុសកូវីដ-១៩ បំប្លែងថ្មី ឆ្លងចូលក្នុងសហគមន៍ អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជន ដែលគុណភាពឥណទានរបស់សម្ព័ន្ធធនាគារ អាចរងផលប៉ះពាល់បន្តិចបន្តួច។

# គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន សម្ព័ន្ធធនាគារ បានផ្តល់អត្រាការប្រាក់មានភាពប្រកួតប្រជែងខ្លាំងចំពោះការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំងអស់អាចដាក់សំណើសុំឥណទានតាម

រយៈ **អេស៊ីលីដាម៉ូបាល**។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៣ មានការកើនឡើងចំនួន ៧៥៧,១៩ ប៊ីលានរៀល ឬ ២,៨៦% ធៀបនឹងដំណាច់ត្រីមាសទី៤ ឆ្នាំ២០២២។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានប្រែប្រួលចន្លោះពី ៤.១០៦ រៀល ទៅ ៤.១៣៣ រៀល ក្នុងមួយដុល្លារអាមេរិក បានឡើងថ្លៃបន្តិចបើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (ចន្លោះពី ៤.១១៨ រៀលទៅ ៤.១៤២ រៀលក្នុងមួយដុល្លារអាមេរិក)។ ការឡើងថ្លៃនៃប្រាក់រៀលគឺមួយផ្នែកដោយសារការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ច តួយ៉ាង វិស័យទេសចរណ៍ និងវិស័យសេវាកម្មផ្សេងៗទៀត ដែលនាំឱ្យមានការកើនឡើងនៃតម្រូវការប្រើប្រាស់ប្រាក់រៀល ហើយផ្នែកសំខាន់មួយទៀតគឺបានមកពីការត្រួតពិនិត្យ គាំទ្រ និងអន្តរាគមន៍របស់ធនាគារជាតិ នៃ កម្ពុជា ក្នុងទីផ្សារប្តូរប្រាក់ ដើម្បីរក្សាស្ថិរភាពនៃប្រាក់រៀល។ ប្រមើលមើលទៅមុខ តម្លៃប្រាក់រៀលត្រូវបានរំពឹងថានឹងបន្តរក្សាបាននូវស្ថិរភាព ដោយយោងទៅលើនិន្នាការនៃតម្រូវការទីផ្សារ និងការផ្គត់ផ្គង់ ការស្ទុះងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច ទំនុកចិត្តពីសាធារណជនលើការប្រើប្រាស់ប្រាក់រៀល និងការបន្តអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិ នៃ កម្ពុជា ដែលបាននឹងកំពុងបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ ដាក់ចេញនូវយន្តការ និងនីតិវិធីផ្សេងៗ ដើម្បីរក្សាបាននូវស្ថិរភាពថ្លៃនៃប្រាក់រៀល។

ចំពោះធនាគារ អេស៊ីលីដា ធនាគារបានធ្វើការវាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងជាប្រចាំថ្ងៃ លើប្រតិបត្តិការក្នុងស្ថានភាពរូបិយប័ណ្ណបើកចំហត្រឹមត្រូវ និងគ្រប់គ្រាន់ ដោយអនុវត្តតាមតម្រូវការបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា និងគោលនយោបាយហានិភ័យផ្ទៃក្នុងរបស់ធនាគារ ដូច្នេះហើយមិនមានផលប៉ះពាល់ជាសារវន្តដល់ធនាគារឡើយ។

**ចំពោះអត្រាការប្រាក់៖** អត្រាការប្រាក់ទាំងនៅទីផ្សារក្នុងស្រុក និងអន្តរជាតិបានបន្តមានស្ថិរភាព ទោះបីស្ថិតក្នុងកម្រិតខ្ពស់បន្តិចក៏ដោយ។ ស្ថិរភាពនេះ បានដើរស្របជាមួយនឹងការផ្អាកមិនដំឡើងអត្រាការប្រាក់ចំនួនបីលើកជាប់ៗគ្នា នៃកិច្ចប្រជុំគោលនយោបាយរបស់ធនាគារកណ្តាលអាមេរិក (គិតត្រឹមខែធ្នូ ឆ្នាំ២០២៣) បន្ទាប់ពីការធ្លាក់ចុះនៃអតិផរណារបស់សហរដ្ឋអាមេរិក។ ទន្ទឹមនឹងនោះ ក្រុមមន្ត្រីរបស់ធនាគារកណ្តាលអាមេរិក បានផ្តល់សញ្ញាណពីការកាត់បន្ថយអត្រាការប្រាក់សម្រាប់ឆ្នាំ២០២៤។ ទោះយ៉ាងណាក៏ដោយ មិនមានផលប៉ះពាល់ជាសារវន្តដល់ធនាគារ អេស៊ីលីដា ទេ ដោយសារថាធនាគារបាននឹងកំពុងដំណើរការអាជីវកម្មរបស់ខ្លួនស្ទើរតែទាំងស្រុងដោយការផ្គូផ្គងផ្នែកទាំងសងខាង (ទ្រព្យសកម្ម និងបំណុល) នៃតារាងតុល្យការ នូវអត្រាការប្រាក់ថេរ ហើយធនាគារបានត្រួតពិនិត្យជាប្រចាំដើម្បីចាត់វិធានការសមស្រប និងទាន់ពេលវេលា ដើម្បីចៀសវាងបានរាល់ផលប៉ះពាល់លើអាជីវកម្មរបស់ធនាគារ។

ដោយឡែកចំពោះប្រតិបត្តិការជួញដូរនានា ដែលមានទម្រង់ជាទំនិញ (Commodities) ធនាគារមិនមានផ្តល់សេវាបែបនោះទេ ដូច្នេះមិនមានផលប៉ះពាល់ដល់ធនាគារឡើយ។

## ង- ផលប៉ះពាល់នៃអតិផរណា

អតិផរណាឆ្នាំ២០២៣ ស្មើនឹង ២,១ ភាគរយ ហើយអតិផរណាត្រូវបានព្យាករថានឹងឈានដល់ ២,៥ ភាគរយ នៅឆ្នាំ២០២៤ ដែលខ្ពស់ជាង ០,៤ ភាគរយ ធៀបនឹងឆ្នាំ២០២៣ ដោយសារការរំពឹងទុកនៃការវិលត្រឡប់ទៅរកភាពប្រក្រតីនៃតម្លៃប្រេងអន្តរជាតិ។ យ៉ាងណាមិញ ហានិភ័យដែលបង្កឡើងដោយភាពមិនប្រាកដប្រជាមួយចំនួនដូចជា ភាពកាន់តែតានតឹងនៃភូមិសាស្ត្រ សេដ្ឋកិច្ច និងនយោបាយ អាចនឹងធ្វើឱ្យអត្រាអតិផរណាងើបឡើងវិញ ដែលនឹងស្តែងចេញពីកត្តាតម្រូវការ និងការផ្គត់ផ្គង់លើទីផ្សារ។ ទោះជាយ៉ាងណាក៏ដោយ ធនាគារបាននឹងកំពុងដំណើរការ មិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកម្រិតអតិផរណានោះទេ។ ដូច្នេះ ផលប៉ះពាល់គឺតិចតួចបំផុត និងអាចគ្រប់គ្រងបាន។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

- **គោលនយោបាយសេដ្ឋកិច្ច៖**

ធនាគារជាតិ នៃ កម្ពុជា បានផ្តល់ជារបាយការណ៍ថា សេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២៣ រំពឹងថានឹងមានកំណើន ៥,៥% ដែលគាំទ្រដោយការកើនឡើងខ្ពស់ នៃវិស័យទេសចរណ៍ និងកំណើនផលិតផលកម្មន្តសាលមិនមែនកាត់ដេរ៖

១. វិស័យទេសចរណ៍មានកំណើនល្អប្រសើរក្នុងអត្រា ១៩,៨% ដោយចំនួនភ្ញៀវអន្តរជាតិបានកើនឡើងដល់ ៥,៥ លាននាក់។

២. វិស័យកម្មន្តសាលបានកើនឡើងក្នុងអត្រា ៧,៤% ដោយផលិតផលកម្មន្តសាលសម្រាប់បម្រើការនាំចេញកើន ៤,៣% ជាពិសេសផលិតផលមិនមែនកាត់ដេរ ដូចជា បរិក្ខារអេឡិចត្រូនិកកើន ១,៣ដង និងយានយន្តនិងគ្រឿងបន្លាស់សម្រាប់យានយន្តកើន ៣,២ដង ខណៈផលិតផលកម្មន្តសាលសម្រាប់បម្រើទីផ្សារក្នុងស្រុកថយចុះ ៧%។

៣. វិស័យកសិកម្មបានកើនឡើង ១,១% ដែលគាំទ្រដោយ កំណើនបរិមាណផលស្រូវ ដំរកៅស៊ូ និងអនុវិស័យជលផល។

៤. ចំណែកឯវិស័យសំណង់និងអចលនទ្រព្យបន្តមានកំណើនយឺតក្នុងអត្រា ១,១% និង ០,៥% រៀងគ្នា។

៥. សមតុល្យជញ្ជីងទូទាត់កម្ពុជាត្រូវបានប៉ាន់ស្មានថាមានអតិរេក ២២៦,១ លានដុល្លារអាមេរិក ដែលគាំទ្រដោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុ ស្របពេលដែលសមតុល្យគណនីចរន្ត និងដើមទុនបានប្តូរពីឱនភាព មកជាអតិរេក។ អតិរេកនេះបានរួមចំណែកបង្កើនទុនបម្រុងអន្តរជាតិដល់ ២០ ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹង ៧ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (៣ខែ)។

ស្របគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏បានព្យាករផងដែរថា សេដ្ឋកិច្ចកម្ពុជាត្រូវបានវាយតម្លៃថានឹងសម្រេចបានកំណើនក្នុងអត្រា ៥,៦% ដូចតាមការប៉ាន់ស្មានកាលពីដើមឆ្នាំ ប៉ុន្តែអនុវិស័យដែលគាំទ្រកំណើនខ្លះមានការប្រែប្រួល។ ផលវិបាកនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន សង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យារវាងចិន-អាមេរិក និងការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ កំពុងធ្វើឱ្យទស្សនវិស័យសេដ្ឋកិច្ចសកលបន្តមានភាពមិនប្រាកដប្រជាខ្ពស់ និងបានដាក់សម្ពាធមកលើអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងការងើបឡើងវិញនៃអនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន និងវិស័យគាំទ្រផ្សេងៗទៀត រួមមាន លក់ដុំ-រាយ និងដឹកជញ្ជូន បន្តចូលរួមចំណែកទ្រទ្រង់កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២៣។ [(១), (២)]

យោងតាមព័ត៌មានដែលបានចុះផ្សាយរបស់ស្ថាប័នល្បីល្បាញមួយចំនួននៅបន្តព្យាករ GDP ឆ្នាំ២០២៣ របស់កម្ពុជាផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានព្យាករសេដ្ឋកិច្ចរបស់កម្ពុជាថា កំណើនសេដ្ឋកិច្ចរបស់កម្ពុជាក្នុងឆ្នាំ២០២៣ នឹងមានកម្រិតទាបជាងការព្យាករមុនបន្តិច ពោលគឺធ្លាក់មកត្រឹម ៥,៣% ពី ៥,៥% ភាគច្រើនដោយសារតែកំណើនឧស្សាហកម្មយឺតជាងការរំពឹងទុកនៅក្នុងឆមាសទីមួយ នេះបើយោងតាមការធ្វើបច្ចុប្បន្នភាពនៃរបាយការណ៍សេដ្ឋកិច្ចរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ របាយការណ៍របស់ ADB បានរក្សាការព្យាករកំណើនឆ្នាំ២០២៤ របស់ប្រទេសនៅត្រឹម ៦%។ ទស្សនវិស័យអភិវឌ្ឍន៍អាស៊ី (ADO) ខែកញ្ញា ឆ្នាំ ២០២៣ កត់សម្គាល់ថា ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរបានធ្លាក់ចុះ ១៨,៦% ធៀបនឹងឆ្នាំមុននៅឆមាសទីមួយនៃឆ្នាំ២០២៣។ នេះត្រូវបានប៉ះប៉ូវមួយផ្នែកដោយការកើនឡើង ២២,៩% នៃការនាំចេញផលិតផលផ្សេងទៀតក្រៅពីសម្លៀកបំពាក់ ដូចជាគ្រឿងបន្លាស់រថយន្ត បន្ទះស្រូបពន្លឺព្រះអាទិត្យ និងគ្រឿងសង្ហារិម។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករថា GDP សម្រាប់ប្រទេសកម្ពុជាគឺ ៥,៦% សម្រាប់២០២៣ និង ៦,១% សម្រាប់២០២៤ នេះបើយោងតាមការចុះផ្សាយនៅលើគេហទំព័ររបស់ពួកគេ (World Economic Outlook)។ ធនាគារពិភពលោក (WB) ២០២៤ បានព្យាករកំណើន GDP សម្រាប់ប្រទេសកម្ពុជាគឺ ៥,៨% សម្រាប់២០២៤ និង ៦,១% សម្រាប់២០២៥ នេះបើយោងតាមការចុះផ្សាយនៅលើគេហទំព័ររបស់ពួកគេ (Global Economic Prospect)។ [(៣), (៤), (៥)]

- **គោលនយោបាយសារពើពន្ធ៖**

សម្រាប់ឆ្នាំ២០២៣ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវវិធានការសំខាន់ៗ និងជាយុទ្ធសាស្ត្រសំខាន់ៗដូចតទៅ៖

(១) បន្តយកចិត្តទុកដាក់ និងពង្រឹងការអនុវត្តការងារស្របតាមអនុសាសន៍របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ជាទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារកាលពីកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំឆ្នាំ២០២២ នាថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣។

(២) អនុវត្តផែនការសកម្មភាពក្នុងការផ្សព្វផ្សាយច្បាប់ស្តីពីសារពើពន្ធថ្មី ជូនដល់អ្នកជាប់ពន្ធ សាធារណជន ព្រមទាំងបន្តរៀបចំធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិនានាស្តីពីពន្ធដារឱ្យស្របតាមច្បាប់ស្តីពីសារពើពន្ធថ្មី។

(៣) បន្តពង្រឹងការផ្តល់សេវាពិគ្រោះយោបល់ និងការផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ តាមគ្រប់រូបភាពជាពិសេសការផ្តល់សេវាពិគ្រោះយោបល់តាមរយៈទូរស័ព្ទ (Call Center-1277) និងការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" (GDT Facebook Live) ដើម្បីពន្យល់និងដោះស្រាយការលំបាកនិងចម្ងល់របស់ប្រជាពលរដ្ឋ។

(៤) រៀបចំសិក្ខាសាលាជាមួយសមាគមសហគ្រិនវ័យក្មេងក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត** លើប្រធានបទពាក់ព័ន្ធនឹងអនុលោមភាពសារពើពន្ធ ក្នុងអំឡុងខែមិថុនា ឬកក្កដា ឆ្នាំ២០២៣។

(៥) ស្នើសុំសហការជាមួយក្រសួងពាណិជ្ជកម្មលើការពង្រឹងការចុះបញ្ជីសហគ្រាសថ្មីព្រមទាំងពង្រឹងប្រសិទ្ធភាពការងារ និងតួនាទីរបស់ភ្នាក់ងារចុះបញ្ជីពាណិជ្ជកម្ម។

(៦) បន្តពង្រឹងការគ្រប់គ្រងប្រមូលពន្ធ តម្លាភាព និងការប្រកួតប្រជែងដោយសេរីភាពក្នុងវិស័យផលិតភេសជ្ជៈ និងផលិតផលបារីនិងថ្នាំជក់ ដើម្បីធានាបាននូវនិរន្តរភាពចំណូលពន្ធដែលជាគុណប្រយោជន៍នៃថវិកាជាតិ។

(៧) រៀបចំប្រព័ន្ធដំណើរការការងាររដ្ឋបាលតាមទម្រង់ឌីជីថល (E-Administration) និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដើម្បីអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធអាចអនុវត្តការងារតាមឋានានុក្រម ដោយប្រើប្រាស់ទម្រង់ឌីជីថល និងធានាបាននូវល្បឿននិងប្រសិទ្ធភាពក្នុងការអនុវត្តការងារ។

(៨) បន្តអនុវត្តវិធានការទារនិងតឹងទារបំណុលពន្ធតាមនីតិវិធីជាធរមាន ចំពោះសហគ្រាសដែលជំពាក់បំណុលពន្ធហើយមិនបានចូលខ្លួនមកទូទាត់ឬដោះស្រាយឱ្យបានត្រឹមត្រូវ។

(៩) បន្តពង្រឹងការងារចុះបញ្ជីពន្ធដារនិងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស និងបន្តសហការចូលរួមកែលម្អ និងជំរុញការងារចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX) ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពគ្រប់ជ្រុងជ្រោយ។

(១០) បន្តផ្សព្វផ្សាយនិងពង្រឹងការអនុវត្តវិធានវិក្កយបត្រក្នុងចំណោមអ្នកជាប់ពន្ធ និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw) ឱ្យមានការចូលរួមបន្ថែមទៀតពីសាធារណជន ដើម្បីធានាបាននូវប្រសិទ្ធភាពនិងតម្លាភាពក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធអាករនានា។

(១១) បន្តពង្រឹងការគ្រប់គ្រងសហគ្រាសស្នើសុំផ្អាកបណ្តោះអាសន្ន ឬស្នើសុំបើកដំណើរការឡើងវិញ និង/ព្យួរទុក ឬបើកដំណើរការវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម។

(១២) បន្តពង្រឹងនិងយកចិត្តទុកដាក់ចំពោះការស្នើសុំបិទសហគ្រាសជាស្ថាពរ និងពង្រឹងលើការងារសវនកម្មសម្រាប់សហគ្រាសស្នើសុំបិទ។

(១៣) បន្តចូលរួមក្នុងក្របខ័ណ្ឌការងារប្រឆាំងនឹងបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ជាមួយគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.) និងអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារវាយតម្លៃត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (អ.អ.ផ.)។

(១៤) បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងកម្មវិធីប្រកបដោយស្មារតីបុរេសកម្ម តាមរយៈការអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាពប្រព័ន្ធនិងកម្មវិធីថ្មីៗ បន្តវិនិយោគ និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងពង្រឹងសមត្ថភាពមុខងារវិភាគទិន្នន័យបន្ថែមទៀត ដើម្បីជំរុញបង្កើនកម្រិតអនុលោមភាពសារពើពន្ធ ដោយធ្វើយ៉ាងណាឱ្យងាយស្រួលក្នុងការបំពេញកាតព្វកិច្ចពន្ធដារ ប៉ុន្តែពិបាកក្នុងការគេចវេះ តាមរយៈការបន្តអភិវឌ្ឍបន្ថែមនូវមុខងារមួយចំនួន តាមធាតុចូលដែលទទួលបានពីអ្នកប្រើប្រាស់ពីគ្រប់មជ្ឈដ្ឋាន ដើម្បីឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយនិងងាយស្រួលក្នុងការប្រើប្រាស់។

(១៥) បន្តអនុវត្តវិធានការបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់បន្តគ្រប់គ្រងផលប៉ះពាល់ និងគាំទ្រការងើបឡើងវិញនៃវិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបន្តកាត់បន្ថយផលប៉ះពាល់មកលើស្ថានភាពសង្គម-សេដ្ឋកិច្ច ព្រមទាំងបន្តជួយទ្រទ្រង់ និងស្តារអាជីវកម្ម និងធុរកិច្ចឱ្យងើបឡើងវិញ។

(១៦) អនុវត្តនូវវិធានការរបស់រាជរដ្ឋាភិបាលសម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យសំណង់ និងអចលនទ្រព្យដើម្បីរក្សាស្ថិរភាពនៃវិស័យសំណង់ និងអចលនទ្រព្យ ដែលត្រូវបានចាត់ទុកជាវិស័យអាទិភាពមួយគាំទ្រដល់កំណើនសេដ្ឋកិច្ចជារួម។

(១៧) បន្តអនុវត្តវិធានការចាំបាច់នានាដូចមានកំណត់ក្នុងសារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ និងបន្តអនុវត្តដោយការយកចិត្តទុកដាក់នូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣។ [៦]

សរុបរយៈពេល១២ខែ ឆ្នាំ២០២៣ ចំណូលពន្ធអាករដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន ១៤.៦២៩,១០ ប៊ីលានរៀល (ប្រមាណជា ៣.៦១២,១២ លានដុល្លារអាមេរិក) ស្មើនឹង ១០១,១៣% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ ចំពោះលទ្ធផលនៃការគ្រប់គ្រងប្រមូលចំណូលពន្ធបានបង្ហាញថា ក្នុងខែធ្នូ ឆ្នាំ២០២៣ ចំណូលពន្ធអាករគ្រប់ប្រភេទដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារមានចំនួន ១.០៧២,៣១ ប៊ីលានរៀល (ប្រមាណជា ២៦៤,៧៧ លានដុល្លារអាមេរិក) ស្មើនឹង ៧,៤១% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ [៧]

- **គោលនយោបាយរូបិយវត្ថុ៖**

សម្រាប់ឆ្នាំ២០២៣ ធនាគារជាតិ នៃ កម្ពុជា បានកំណត់អនុវត្តន៍គោលនយោបាយរូបិយវត្ថុចំនួន៥ ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារកំណើនសេដ្ឋកិច្ចជាតិ រួមមាន៖

(១) គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប
(២) រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែកស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន
(៣) លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារ
(៤) អភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុថ្មីៗ និង
(៥) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។ [៨]


ឯកសារយោង:

(១) https://www.nbc.gov.kh/download_files/publication/annual_rep_kh/Annual_Report_2023_KHM.pdf
(២) https://mef.gov.kh/documents/9273/ Release on 04-Aug-2023
(៣) https://www.adb.org/news/adb-adjusts-2023-growth-forecast-cambodia-maintains-2024-outlook
(៤) https://www.imf.org/en/Publications/WEO/Issues/2023/10/10/world-economic-outlook-october-2023
(៥) https://www.worldbank.org/en/publication/global-economic-prospects
(៦) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/4a00be95-27f8-48cb-a476-f3b7dcdcfa26
(៧) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/2e8790c9-020b-453f-b743-4b1bad3729a8
(៨) https://www.nbc.gov.kh/download_files/publication/annual_rep_kh/Semi%20Annual%20Report%202023%20Publish_KHM.pdf


**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៤
បានអាន និងឯកភាព
ហត្ថលេខា

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

**ឆាយ សឿន**
**ប្រធានក្រុមប្រឹក្សាភិបាល**

ការិយាល័យកណ្តាល ៖ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ | ទូរសារ ៖ ០២៣ ៤៣០ ៥៥៥
acledabank@acledabank.com.kh | www.acledabank.com.kh
ប្រអប់សំបុត្រលេខ ៖ ១១៤៩ | SWIFT Code ៖ ACLBKHPP

ការិយាល័យទំនាក់ទំនងអតិថិជន (បម្រើ ២៤ម៉ោង)
ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
inquiry@acledabank.com.kh